**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦២ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការចាត់តាំងក្រុមការងាររៀបចំរចនាសម្ព័ន្ធ និងមន្ត្រីរាជការនៅក្នុងរដ្ឋបាលខេត្តត្បូងឃ្មុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតខេត្តត្បូងឃ្មុំ
- យោងសេចក្ដីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ .-**

ត្រូវបានចាត់តាំងមន្ត្រីរាជការចំនួន ០៧រូប ជាក្រុមការងារសម្រាប់រៀបចំរចនាសម្ព័ន្ធ និងមន្ត្រីរាជការក្នុងរដ្ឋបាលខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្ដម **ប្រាជ្ញ ចន្ទ** | ទីប្រឹក្សារាជរដ្ឋាភិបាល | ប្រធាន |
| ២-លោក **លី ឡេង** | មន្ត្រីទីស្ដីការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-លោកស្រី **ឡេង សុខា** | ប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ចាម | សមាជិក |
| ៤-លោក **ម៉ែន កុសល** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោក **អ៊ុយ សុធាទី** | នាយករងរដ្ឋបាលសាលាខេត្តបាត់ដំបង | សមាជិក |
| ៦-ឯកឧត្ដម **ឃាត់ សុខមករា** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧-លោក **គន់ សុភា** | មេបញ្ជាការរង នៃបញ្ជាការដ្ឋានកងរិស្វកម្មអគ្គបញ្ជាការ | សមាជិក ។ |



www.pheakdeylaw.com

**ប្រការ ២ .-**

ក្រុមការងាររៀបចំរចនាសម្ព័ន្ធ និងមន្ត្រីរាជការនៅក្នុងរដ្ឋបាលខេត្តត្បូងឃ្មុំ មានភារកិច្ចដូចខាងក្រោម :

- បំពេញភារកិច្ចប្រចាំការនៅទីតាំងរដ្ឋបាលបណ្តោះអាសន្ន ដែលស្ថិតនៅសាលាស្រុកពញាក្រែក ដើម្បីធ្វើជាសេនាធិការដល់គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ ក្នុងការជួយសម្របសម្រួលរៀបចំរចនាសម្ព័ន្ធ និងមន្ត្រីរាជការក្នុងរដ្ឋបាលខេត្តត្បូងឃ្មុំ ។

- សហការជាមួយរដ្ឋបាលខេត្តកំពង់ចាម ដើម្បីឈានទៅធ្វើការប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តត្បូងឃ្មុំ ។

- បំពេញការងារចាំបាច់ផ្សេងទៀត តាមការប្រគល់ភារកិច្ចពីប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំរដ្ឋបាលខេត្តត្បូងឃ្មុំ ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*



www.pheakdeylaw.com